# ការសំភាសន៍របស់អ្នកមីង សាយ សំអាន

**កៈ អ្នកសំភាសន៍កុសល្យ វឌ្ឍនៈនិមល      ខៈ អ្នកត្រូវគេសំភាសន៍សាយ សំអាន**

កៈ អញ្ចឹងមីងអើជាដំបូងខ្ញុំសូមអរគុណមីងដែរបានអនុញ្ញាតិអោយខ្ញុំមកសំភាសន៍មីងថ្ងៃហ្នឹង ហើយអើខ្ញុំនាក់សំភាសន៍គឺឈ្មោះកុសល្យ វឌ្ឍនៈ និមល ហើយថ្ងៃខែដែរសំភាសន៍ គឺនៅថ្ងៃទី ១២ ខែ១១ ឆ្នាំ២០១៧។ ហើយទីតាំងដែរសំភាសន៍គឺនៅភូមិទ្រា២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌ័មានជ័យ ក្រុងភ្នំពេញ។

ហើយអញ្ចឹងមីងអើការសំភាសន៍នេះគឺត្រូវអើបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅសហាតដ្ធអាមេរិកដែរមានឈ្មោះថា BYUហើយគោលបំណងរបស់សាលាគឺចង់ជួយដល់ប្រជាជនខ្មែរទាំងអស់ដើម្បីពួកគាត់អាចមានឧកាសថែរក្សាប្រវត្តិផ្ទាល់ខ្លួនទុកដល់កូនចៅជំនាន់ក្រោយៗទៀតរបស់នាក់មីងហ្អាដើម្បីពួកគាត់អាចមានឪកាសរៀននឹងអើស្ដាប់ពីការផ្ដែផ្ដាំរបស់មីងនៅក្នុងជីវិតរបស់មីងអញ្ចឹងហ្អាណាមីង។ ហើយអញ្ចឹងមីងអើជាដំបូងខ្ញុំចង់សួរថា តើមីងមានឈ្មោះពេញឈ្មោះក្នុងអតសញ្ញាណបទឈ្មោះអីគេដែរ?

ខៈ ឈ្មោះ សាយ សំអាន។

កៈ សាយ សំអាន?

ខៈ ចាស។

កៈ ចាស ហើយចុះអើ មីងមានឈ្មោះហៅក្រៅហ្អេស?

ខៈ អត់មានផង។

កៈ អត់មានទេ?

ខៈ ចាស។

កៈ ចាស ហើយចុះអើអាយុមីងបើគិតមកដល់ឥឡូវអាយុមាណហើយ?

ខ៖ ៣៧ឆ្នាំហើយ។

ក៖ ៣៧ឆ្នាំ?

ខ៖ ចាស។

ក៖ ចុះអើ មីងកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

ខ៖ អត់ចាំផង។

ក៖ អត់ចាំសោះមងមីងណា?

ខ៖ ចាស។

ក៖ ចាស ចុះអើឆ្នាំខ្មែរមីង ឆ្នាំអីគេ?

ខ៖ ឆ្នាំខ្មែរ ឆ្នាំវក។

ក៖ ឆ្នាំវកអើ ឆ្នាំសត្វស្វា?

ខ៖ សត្វស្វា។

ក៖ ចាសចាស ចុះអើមីងកើតនៅទីកន្លែងណាដែរ? ដូចជាភូមិអី? ស្រុកអីអញ្ចឹងហ្អា?

ខ៖ ភូមិជង្រុក ស្រុកកងពិសី ខេត្តកំពង់ស្ពឺ ។

ក៖ ភូមិជង្រុក ស្រុក?

ខ៖ ឃុំ។

ក៖ ឃុំជង្រុក ស្រុកកងពិសី?

ខ៖ ស្រុកកងពិសី ភូមិកំពង់ស្ពឺ ភូមិក្របីត្រាំ។

ក៖ ហ្អរចាស ហើយចុះមីងមានបងប្អូនមាណនាក់ដែរ?

ខ៖ ខ្ញុំបីនាក់។

កៈ ចាស ហើយមីងជាកូនទីមាណ?

ខៈ កូនទីមួយ។

កៈ ចាស ហើយចុះមីងអាចអើ ប្រាប់ឈ្មោះបងប្អូនរបស់មីងទាំងអស់បានហ្អេស?

ខៈ បងទីមួយឈ្មោះសាយ សំអឿន។

កៈ ចាសទីពី?

ខៈ ទី ទីពីឈ្មោះអើ សាយ ចេនឡា។

កៈ សាយ ចេនឡា?ហើយបន្ទាប់មីង។

ខៈ ខ្ញុំឈ្មោះ សាយ សំអាន។

កៈ សាយ សំអាន?

ខៈ ចាស។

កៈ ចាស
អញ្ចឹងអើតើមីងនៅចងចាំសាច់រឿងអីខ្លះ? នៅពេលដែរមីងនៅក្មេងៗជាមួយបងប្អូនមីងហ្អា? តើដូចបានមានអនុស្សាវរីយ៍អីខ្លះជាមួយគ្នារ?

ខៈ ដូចអត់មានអនុស្សាវរីយ៍អីផង ព្រោះអើបើប្អូនខ្ញុំអាពៅគេ ហ្នឹងខ្ញុំខំបានមើលថៃគាត់។

កៈ ចាស។

ខៈ
ហ្នឹងហើយ ខ្ញុំមើលថៃគាត់ ព្រោះម្តាយខ្ញុំគាត់ដើរទៅរកស៊ីណាបាត់ៗទៅ មានតែខ្ញុំបងគេហ្នឹងនៅមើលបីបាច់ថែរក្សាប្អូនរហូតដល់ធំអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហ្នឹងហើយ ដល់ពេលធំពេញវ័យឡើង គាត់ទៅនៅវត្តនៅអីទៅ គាត់ចេះរកដើម្បីចញ្ចឹមខ្លួនឯងអញ្ចឹងទៅ។

ក៖ ចាសចាស។

ខ៖ ហ្នឹងហើយ ហើយបើប្រវត្តិអនុស្សាវរីយ៍អីដូចអត់មាន។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖ ចាស ហើយចុះអើពេលដែរនាក់មីងនៅក្មេង តើចូលចិត្តធ្វើអ្វីខ្លះជាមួយនឹងពួកគាត់? ដូចជាបានអើមានអនុស្សាវរីយ៍? ដូចជាទៅលក់នំជាមួយគ្នារឬអីជាមួយគ្នារហ្អេស?

ខ៖ អត់។

ក៖ អត់ដែរសោះ?

ខ៖ អត់ដែរមានអនុស្សាវរីយ៍អីតិចផង។

ក៖ ចាសចាស។

ខ៖ ហ្នឹងហើយ។

ក៖ ចាស។

ខ៖ ហើយ បើ
បើអនុស្សាវរីយ៍លេងអីជាមួយគ្នារអាចមានតិចតួច លេងដូចជាគេលេងជាល្ខោន លេងជាអីអញ្ចឹង លេងបីឡុកបីឡូរអីជាមួយគ្នារ ហ្នឹង ហ្នឹងចេះតែមានហើយតិចតួច។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖ ហើយចុះអើ នៅពេលនេះបងប្អូនមីងទាំងអស់ ពួកគាត់រស់នៅកន្លែងណាខ្លះដែរ?
ខ៖ អាពៅគេនៅអើ សៀមរាប។

ក៖ ចាស។

ខ៖ ដល់តែពេលប្អូនមួយទៀតនៅអើកំពង់ស្ពឺជាមួយម្ដាយ។

ក៖ ចាស។

ខ៖ ចាស។

ក៖ ហើយបងនៅភ្នំពេញ?

ខ៖ ខ្ញុំនៅភ្នំពេញ។

ក៖ ហ្អរចាស ហើយអើ តើម្ដាយរបស់នាក់មីងគាត់ឈ្មោះអីគេ?

ខ៖ មាន ផេង។

ក៖ មាន ផេង?

ខ៖ ចាស មានផេន។

ក៖ ចាស ហើយ ផេន ផេន?

ខ៖ មាន ផេន។

ក៖ ចាស ហើយចុះឪពុក?

ខ៖ ឪពុកឈ្មោះខន។

ក៖ ឈ្មោះខន?

ខ៖ ចាស ប៉ុន្តែខ្ញុំអត់ចាំត្រកូល អត់ស្គាល់ត្រកូលគាត់ផង។

ក៖ ចាស ហើយចុះអើពួកគាត់ទាំងពី បើគិតមកដល់ឥឡូវគាត់មានអាយុមាណអស់ហើយ?

ខ៖ អើ បើខ្ញុំម្ដាយខ្ញុំអាយុហាជាងហើយ។

ក៖ ចាស ចុះឪពុក?

ខ៖ បើឪពុកខ្ញុំ ខ្ញុំអត់ចាំទេ អត់ស្គាល់ ដឹងអាយុគាត់មាណទេ។

កៈ ចាសចាស ហើយចុះអើ ពួកគាត់ទាំងពីអើ នាក់មីងចាំថាពួកគាត់កើតនៅថ្ងៃណា ខែណា ឆ្នាំណា ហ្អេស?

ខៈ ខ្ញុំអត់ចាំផងឪពុកខ្ញុំ បើម៉ែខ្ញុំ ខ្ញុំចាំតែគាត់កើតឆ្នាំអើ ឆ្នាំឆ្កែរ ឆ្នាំ?

កៈ ឆ្នាំចរ?

ខៈ ឆ្នាំចរ។

កៈ ចាសចាស។

ខៈ ប៉ុន្តែមិនដឹងគាត់កើតថ្ងៃណាខែណាខ្ញុំអត់ដឹង។

កៈ ហ្អរ ចាសចាស ហើយចុះអើដឹងថាគាត់កើតនៅទីកន្លែងណាហ្អេស? ដូចជានៅភូមិអី ស្រុកអីអញ្ចឹងហ្អា។

ខៈ បើគាត់កើត មានតែកើតនៅអើ កំពង់ស្ពឺ ខេត្តកំពង់ស្ពឺ ។

កៈ ចាស ចាស

ខៈ ប៉ុន្តែគ្រាន់តែថាយាយតាខ្ញុំគាត់មាន គេអាករមានដីផ្ទះអីនៅហ្នឹង ពីដើមអញ្ចឹងទៅណា។

កៈ ចាស ចាស ។

ខៈ ហ្នឹងហើយ អញ្ចឹងមានគាត់កើតនៅខេត្តកំពង់ស្ពឺហ្នឹង។

កៈ ចាស។

ខៈ ហ្នឹងហើយ។

កៈ ហើយចុះអើ ឪពុករបស់នាក់មីង គាត់បានប្រកបមុចរបរអីគេខ្លះដើម្បីចញ្ចឹមជីវិតគាត់ដែរ។

ខៈ ខ្ញុំអត់ចាផង ខ្ញុំបែកគាត់តាំងពីខ្ញុំនៅតូចមក។

កៈ អញ្ចឹង? មេចអញ្ចឹងបង?

ខៈ ដ៏អញ្ចឹងខ្ញុំអត់ចាំ។ ព្រោះគាត់បែកពីម្តាយខ្ញុំតាំងពីខ្ញុំកើតបានបួនខែហ្នឹងមក។

កៈ ហ្អរ។

ខៈ លេងគ្នារ។

កៈ ចាស។

ខៈ ហ្អឺ។

កៈ ហើយអើបង? អើនាក់មីងដឹងថាគាត់ជាមនុស្សបែបណាហ្អេស? ដូចជាកាចឬក៏ស្លូត។

ខៈ តាមម៉ែខ្ញុំគាត់និយាយថា គាត់មនុស្សគាត់ស្លូតណាស់ ឪពុកខ្ញុំនោះ។

កៈ ចាស។

ខៈ ស្លូតដូចខ្ញុំអញ្ចឹងហិហិហិ។

កៈ ហិហិហិហិហិហ្អរស្លូតដូចបង?

ខៈ ហ្អឺ។

កៈ ហិហិ ហើយចុះអើ ចុះម្ដាយរបស់នាក់មីងវិញ តើគាត់បានប្រកបមុខរបរអីខ្លះដើម្បីចញ្ចឹមជីវិតគាត់ដែរ?

ខៈ គាត់លក់នំ ជូនអីគាត់ដើររកនេះរកនោះលក់អញ្ចឹងទៅណា។

កៈ ចាស។

ខៈ កាត់ដើរលក់នំ តិចទៅគាត់ដើរបេះនេះបេះនោះអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ តាមពីខ្ញុំដឹងក្ដីគាត់ មិនដែរឃើញរកស៊ីកាងាធំដុំអីផង គាត់គ្រាន់តែដើបេះនេះបេះនោះលក់នំតាមបុណ្យតាមអីតិចតួចហ្អា។

កៈ ចាស។

ខៈ ហ្នឹងហើយ មានតែប៉ុណ្ណឹង។

កៈ ចាស ហើយចុះគាត់ជាមនុស្សបែបណាដែរ? ដូចជាកាចឬក៏ស្លូត?

ខៈ តាមអើ ម៉ែខ្ញុំដូចមិនកាចអីណាស់ណា ប៉ុន្តែគាត់មនុស្សអើគំនិតអត់កើត។

កៈ ចាស។

ខៈ និយាយអញ្ចឹងមងទៅហិហិហិហិហិ។

កៈ ចាសចាស គាត់នៅគំនិតអត់កើតដោយសារអី? គាត់ដឹងតែពីលក់ អត់ដែរថាអត់អើគិតអើទុកដើម្បីខ្លួនចាស់ អត់មានគិតថាទុកដើម្បីអនាគតកូនអីអញ្ចឹងទៅណា។ ដឹងតែពីលក់អស់អញ្ចឹង ដូចស្រែ ដូចដីអញ្ចឹងគាត់លក់ខ្ទេចអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហ្នឹងហើយ លក់តាំងពីខ្ញុំនៅតូចៗហ្អរ។

កៈ ហ្អឺ។

ខៈ ខ្ញុំដឹងហើយ ខ្ញុំមិនដែរមានស្រែ
មានភ្លឺនឹងគេ មិនដែរឃើញមានដីមានអីដើម្បីទុកចែកកូនអត់ផង។

កៈ ហ្អឺ។

ខៈ ដឹងតែថា ដឹងក្តីពេលណា ដឹងតេពិបាក រហូត។

កៈ ហ្អរ។

ខៈ រកស៊ីចញ្ចឹម ជីវិតខ្លួនឯងរហូត។

កៈ ដើម្បីអី? ដើម្បីបើយើងអត់ចេះប្រឹងរកនេះរកនោះលក់ វាអត់មានអីចាយព្រោះយើងអត់មាននាក់ណាចញ្ចឹមយើង។ ម៉ែយើងនោះដើរឆ្ងាយបាត់ៗ ទៅរកស៊ីណាអីណាអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ យើងនៅជាមួយជីដូនអញ្ចឹងទៅ ជីដូនគាត់ចាស់ហើយ គាត់ទៅរកអីបានអោយយើងហូប។

កៈ ចាស។

ខៈ ហ្នឹងហើយ យើងមានតែដើរបេះបួចនេះបេះបោចនោះដើម្បីចញ្ចឹមជីវិតខ្លួនឯងអញ្ចឹងទៅណា។

កៈ ចាសចាស។

ខៈ ហ្នឹងហើយ ហើយដល់ពេលរហូតដល់ខ្ញុំមាន ខ្ញុំចេះតែដើនៅជាមួយគេនៅជាមួយអី ខ្ញុំចេះតែដើៗ ខ្ញុំបានជួបប្ដីខ្ញុំហ្នឹងនៅតែម៉ែខ្ញុំគាត់រករឿងរកអីអញ្ចឹងទៅណា។នៅវាមិនកើតជាមួយគាត់អញ្ចឹងទៅណា។

កៈ ចាស។

ខៈ អញ្ចឹងបានប្ដីខ្ញុំគាត់អាណិតខ្ញុំឃើញពិបាកគាត់ឃើញកំព្រាអីអញ្ចឹងបានគាត់អាណិតហ្នឹងណា បានគាត់មិនដាច់ចិត្តពីខ្ញុំអញ្ចឹងទៅណា។

កៈ ចាស។ ហើយចុះអើ តើនាក់មីងចងចាំសាច់រឿងអីខ្លះអំពីឪពុកម្ដាយនាក់មីងហ្អេស? ដូចជាតើមានអនុស្សាវរីយ៍អីខ្លះជាមួយពួកគាត់ហ្អេស?

ខៈ ខ្ញុំដូចអត់មានអនុស្សាវរីយ៍អីផង។

កៈ ចាស។

ខៈ ដឹងតែពីធ្វើបាបកូនរហូត។

កៈ ហ្អឺ។

ខៈ អត់មានអីគួអនុស្សាវរីយ៍ជាមួយគាត់សោះម៉ងហ្អា។

កៈ ចុះធ្លាប់ជួយលក់នំគាត់ហ្អេស?

ខៈ ធ្លាប់ទៅជួយលក់នំ ប៉ុន្តែជួយលក់នំអញ្ចឹងទៅ គាត់ចេះតែធ្វើបាប តាមផ្លូវតាមអីរហូតចឹងទៅ ត្រូវវៃយើងតាមផ្លូវតាមអីចឹងទៅណា។

កៈ ចាស ។

ខ៖ ចេះតែធ្វើ ធ្វើមេច ធ្វើមិនអោយកូនមានអនុស្សាវរីយ៍អីជាមួយម្ដាយតិចសោះម៉ងណា។

ក៖ ចាស។

ខ៖ ហ្នឹងហើយ។

ក៖ ហ្អឺ ហើយចុះអើ ពួកគាត់ធ្លាប់ប្រាប់អីខ្លះដល់នាក់មីងអំពីជីវិតរបស់ពួកគាត់ នៅពេលដែរពួកគាត់នៅក្មេងហ្អេស? តើពួកគាត់បានឆ្លងកាត់អីខ្លះកន្លងមកហ្អា?

ខ៖ គាត់អត់មានបានប្រាប់អីផង។

ក៖ ហ្អឺ។

ខ៖ គាត់អត់មានបានប្រាប់ពីប្រវត្តិគាត់មេចៗ គាត់អត់មានបានប្រាប់កូនទេ។

ក៖ ហ្អឺ ។

ខ៖ គាត់អត់សោះម៉ង ម៉ែខ្ញុំចប់ម៉ង ហិហិហិហិ។

ក៖ ហិហិហិហិ។ ចុះអើតើនាក់មីងនៅចងចាំឈ្មោះរបស់ជីដូនជីតារបស់នាក់មីងទាំងខាងម្ដាយនឹងខាងឪពុកហ្អេស?

ខ៖ ខ្ញុំចាំតែខាងម្ដាយខ្ញុំទេ ខាងឪពុកខ្ញុំអត។

ក៖ ចាស គាត់ឈ្មោះអី?

ខ៖ អើគាត់ អើឈ្មោះ ហឹម។

ក៖ ហឹម ហ្នឹងជាតាឬក៏យាយ?

ខ៖ យាយ យាយអើ យាយខឹម តាសួន។

ក៖ យាយ ហឹម តាសួន?

ខ៖ ហ្នឹងហើយ។

ក៖ ហ្នឹងខាងម្ដាយ?

ខ៖ ខាងម្ដាយខ្ញុំ។

ក៖ ចាស ចុះអើ តើនាក់មីងចងចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ហ្អេស? ថាគាត់កើតនៅថ្ងៃណា ខែណា ឆ្នាំណាអញ្ចឹងហ្អា?

ខ៖ ខ្ញុំអត់ចាំផង ។

ក៖ អត់ចាំទេ?

ខ៖ ចាស អត់ចាំ។

ក៖ ចុះចាំពីទីកន្លែងកំណើតគាត់ហ្អេស?

ខ៖ ទីកន្លែងកំណើតគាត់ខ្ញុំក៏អត់ចាំដែរ។

ក៖ ហ្អរ ចាសចាស ប្រហែលនៅកំពង់ស្ពឺ ជាមួយគ្នារ? ឬក៏?

ខ៖ មិនដឹងជាគាត់នៅ ប្លុងណាទីណាទេ ប៉ុន្តែបើឮសូម៉ែខ្ញុំថា បើគាត់នៅកំពង់ស្ពឺ នឹងមានមិនដឹងស្រុកកំណើតគាត់ពិតប្រាកដដឹងនៅណាផង។

ក៖ ចាសហ្អរ ចាសចាស។

ខ៖ ហ្អឺ។

ក៖ ហើយចុះអើ តើនាក់មីងមានដឹងធ្លាប់ដឹងរឿងអីខ្លះអំពីជីដូនជីតារបស់នាក់មីងហ្អេស? ថាតើពួកគាត់បានមានជីវិតបែបណាខ្លះ? នៅពេលដែរពួកគាត់នៅក្មេងៗហ្អា?

ខ៖ ខ្ញុំអត់ដឹងកាលគាត់នៅក្មេង ប៉ុន្តែខ្ញុំបើតាមខ្ញុំអើ មើលជីវិតជីដូនរបស់ខ្ញុំ គាត់តស៊ូដើម្បីរកចញ្ចឹមចៅ ដើម្បីគាត់សន្សំសំចៃដើម្បីទុកអោយកូនទុកអោយចៅអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ ស្រែធ្លី ដីធ្លី គាត់ខំមើលថែដើម្បីទុកអោយកូនអញ្ចឹងទៅណា ដល់ពេលមកដល់ដៃម៉ែខ្ញុំទៅម៉ែខ្ញុំលក់អស់អីអញ្ចឹងទៅណា ។

ក៖ ចាស។

ខ៖ តាំងពីខ្មោចយាយខ្ញុំនៅ គាត់នៅក្មេងហ្នឹងគាត់
 សល់បានដី ឬមួយបានដីភូមិដីស្រែទុកអោយកូន ដល់បានមកដល់ម៉ែខ្ញុំនេះ មានទុកអោយកូនទេលក់ខ្វេច។

ក៖ ហិហិហិលក់ទាំងអស់ម៉ង?

ខ៖
 លក់អស់ ស្រែខ្ញុំច្រើន បើខ្ញុំ បើនៅទាល់តែរាល់ថ្ងៃនេះ បើម៉ែខ្ញុំមានគំនិតហ្អា ពួកខ្ញុំអត់ពិបាកហ្អេស។

ក៖ ហ្អរ។

ខ៖ ព្រោះស្រែខ្ញុំធំៗ ហើយអើដីខ្ញុំសុទ្ធតែជាប់ថ្នល់។

ក៖ ចាស។

ខ៖ ហ្អឺ ហើយឥឡូវដីថ្លៃៗហ្អា។

ក៖ ហើយឥឡូវគាត់លក់អស់?

ខ៖ លក់អស់ហើយ រាល់ថ្ងៃមានដីណានៅ នៅដីគេហ្នឹង។

ក៖ អញ្ចឹង?

ខ៖ លក់អស់ ដីភូមិអីរិន លក់អស់ហើយ ហើយទៅនៅជាប់អាដីភូមិឯលក់អោយគេហ្នឹងទៀត។

ក៖ ហ្អឺ។

ខ៖ ហើយគាត់អត់ខ្មាស់គេសោះ គាត់ធ្វើរំភើយ គាត់ថាដូចអត់ខ្វល់ម៉ងហ្អា។

ក៖ ចាស។

ខ៖ ខ្ញុំទៅលេងម្ដងៗហ្អា អត់ចេះខ្មាស់គេ ហ្អឺកូនមកលេងម្ដងៗរកផ្ទះអោយកូនដេកអត់បាន គាត់អត់គិតសោះម៉ង  ហើយខ្ញុំទិញដីនៅហ្នឹងបានមួយដុំអោយគាត់នៅ គាត់អត់នៅទេ គាត់ថាអត់ផ្លូវគាត់ថាពិបាកតភ្លើងអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហ្នឹងហើយ ខ្ញុំប្ដីប្រពន្ធខ្ញុំ ខ្ញុំខំនឹកឃើញម្ដាយអត់មានអីនៅក៏ទិញទុកទៅ ដីហ្នឹងវាថោក។

កៈ ចាស។

ខៈ បណ្ដោយអើជិតម្ភៃ ថាបណ្ដោយម្ភៃចុះ ហើយអើទទឹងមួយដន្តប់ម៉ែត្រ។

កៈ ចាស។

ខៈ ហើយល្មមមាធ្វើផ្ទះនៅហើយ អោយគាត់ទៅនៅ គាត់ថាពិបាកភ្លើង ពិបាកអត់ផ្លូវ តាមការពិតផ្លូវមានមាដើរ ចុះយើងមានឡានមានអីណាចូល។

កៈ ចាស។

ខៈ គាត់អត់ព្រមនៅថាពិបាកតភ្លើង ហើយបង្គោលភ្លើងក៏ជិតដែរ។

កៈ ចាស។

ខៈ គាត់អត់នៅ
ប្ដីខ្ញុំថាបើគាត់មិននៅអត់ទៅ លក់ចោលវិញទៅ នឹកឃើញអាណិតអីអញ្ចឹងហ្អាណា។

កៈ ចាស។

ខៈ យើងចង់អោយនៅ កុំអោយចង់នៅដីគេអញ្ចឹងទៅណា។

កៈ ចាស។

ខៈ អត់ គាត់ថាអត់នៅ អត់នៅ ទុកចោលហ្នឹង ឥឡូវគេអោយថោកពេក។

កៈ ហ្អរ។

ខៈ ហើយខ្ញុំទិញតែ២០០ហ្នឹងដីហ្នឹងហ្អរ។

កៈ ហ្អរ ចាស។

ខៈ ហើយឥឡូវគេអោយ២០០វិញខ្ញុំលក់ធ្វើអី។

កៈ ហ្អរហ្នឹងហើយ។

ខៈ គេចង់ទិញធ្វើផ្លូវអីអញ្ចឹងហ្អា។

កៈ ចាស។

ខៈ អត់លក់ទេទុកចោលហ្នឹង ព្រោះដីហ្នឹងធ្វើផ្ទះបាននៅ។

កៈ ចាសចាស។

ខៈ ហ្នឹងហើយ ហើយខំទិញទុកហ្នឹងទៅ ស្រុកភូមិហ្នឹងទៅ ហើយដើម្បីអោយគាត់នៅអញ្ចឹង ទៅណា។

កៈ ចាស។

ខៈ គ្រែងលោគេដេញពីដីគេណោះមក មកដីខ្ញុំនេះទៅ។

កៈ ចាសចាស។

ខៈ ហ្អឺ ដល់ពេលគាត់គិតអញ្ចឹង គាត់គិតអត់ខ្វល់អត់ពិបាកហ្អា ហើយខ្ញុំពិបាកចិត្តជួសគាត់។

កៈ ធម្មតាយើងកូន។

ខៈ ចាស ហើយអើ ទៅម្ដងៗអញ្ចឹង ខ្មាស់គេដោយសារហ្អឺ អត់មានផ្ទះដេក។

កៈ ហ្អឺ។

ខៈ ហើយជួនកាលអត់ដែរទៅស្រុក។

កៈ ចាស។

ខៈ ខ្ញុំអត់ដែរទៅស្រុកអើ ដោយសារអីវាពិបាកផ្ទះដេកអញ្ចឹងហ្អា។

កៈ ចាសចាស។

ខៈ ដំអញ្ចឹងអើ ប្ដីខ្ញុំគាត់ចេះតែខ្ជិលទៅ ដេកផ្ទះគេអញ្ចឹងខ្មាស់គេ។

កៈ ចាសបងចាស។

ខៈ អញ្ចឹងបានថា ខ្ញុំលែងចង់ទៅស្រុកទៀតហើយឥឡូវ។

កៈ ហ្អឺ ហើយចុះអើ តើក្រុមគ្រួសាររបស់នាក់មីងមករស់នៅទីក្រុងភ្នំពេញអស់រយះពេលមាណាឆ្នាំហើយ?

ខៈ អើគ្រុមគ្រួសារខ្ញុំដូចជាដប់ឆ្នាំហើយ។

កៈ ដប់ឆ្នាំ?

ខៈ ដូចជាដប់ឆ្នាំជាងឬដប់ តាំងពីកូនខ្ញុំបានប្រាំខែ អាបង ឥឡូវកូនខ្ញុំ១៦ហើយ។

កៈ អញ្ចឹងអើ ដប់ឆ្នាំជាង?

ខៈ ដប់ឆ្នាំជាងហើយ ។

កៈ ហ្អរ យូហើយណា?

ខៈ ចាស តាំងពីខ្ញុំការហើយម្លេះហ្នឹង។ ខ្ញុំចេញមករហូត។

កៈ ចាសចាស។ ហើយចុះអើ តើអើនាក់មីងមានសាច់ញាតិណាទៀតដែររស់នៅក្រៅប្រទេសខុសពីស្រុកខ្មែរហ្អេស?

ខៈ អត់មានផង។

កៈ អត់មានសោះម៉ង?

ខៈ ចាស។

កៈ ចាស ហើយចុះអើ តើស្វាម៉ីរបស់នាក់មីងគាត់ឈ្មោះអីគេដែរ?

ខៈ គាត់ឈ្មោះព្រាប សារិត។

កៈ ព្រាប សារិត?

ខៈ ហ្អឺ។

កៈ អញ្ចឹងអើ តើនាក់មីងរៀបការ រៀបអាពាហ៍ពិពាហ៍នៅពេលណាដែរ? ដូចជាថ្ងៃណា ខែណា ឆ្នាំណា?

ខៈ ហ្អារ ខ្ញុំអត់ចាំឆ្នាំខែហ្អេ ប៉ុន្តែខ្ញុំចាំអើ ដូចជាអើឆ្នាំ២០០១។

កៈ ២០០១?

ខៈ ចាស ដូចជា២០០១ អើ ក្នុងខែ ១១។

កៈ ក្នុងខែ១១?

ខៈ ចាស ប៉ុន្តែមិនដឹងថ្ងៃណា។

កៈ ចាស។

ខៈ ខ្ញុំអត់ដឹង ខ្ញុំអត់ចាំ។

កៈ ចាស។ ហើយចុះអើ តើនាក់មីងរៀបចំអាពាហ៍ពិពាហ៍ដោយឪពុកម្ដាយ ឬក៏វាដោយខ្លួនឯង?

ខៈ រៀបចំវាដោយឪពុកម្ដាយ។

កៈ អញ្ចឹងហ្អារ?

ខៈ ចាស។

កៈ ចាស។ ហើយអើ នៅពេលដែរនាក់មីងរៀបអាពាហ៍ពិពាហ៍ មុននាក់មីងរៀបអាពាហ៍ពិពាហ៍ហ្នឹង តើអើ នាក់មីងបានទទួលថ្លៃជំនូនហ្អេស?

ខៈ អត់ផង។

កៈ អញ្ចឹងហ្អារ?

ខៈ ចាស។

កះ ចាស អញ្ចឹងអើ តើនាក់មីងអាចប្រាប់ខ្ញុំបានហ្អេស អំពីមូលហេតុដែរនាក់មីងបានជួបគ្នារជាមួយហ្នឹងស្វាម៉ីនាក់មីងហ្អា? តើហេតុអីបានជួបគ្នារ? ហេតុអីបានស្រឡាញ់គ្នារ? ហើយរហូតដល់ពេលរៀបការអញ្ចឹងទៅណា?

ខះ ខ្ញុំជួបគាត់អើ  នៅកន្លែងធ្វើការអញ្ចឹងទៅ គាត់ដូចថា គាត់មើលទៅគាត់មានចិត្តអាណិតអីអញ្ចឹងទៅណា។

កះ ចាស។

ខះ ចាស ដល់ពេលនេះទៅ គាត់មានចិត្តអាណិត តាមស្រឡាញ់ក៏អត់ស្រឡាញ់ដែរតែគាត់អាណិត។

កះ ចាស។

ខះ ហ្នឹងហើយ គាត់អាណិតអញ្ចឹងទៅ គាត់អើមាននាក់ធ្វើការជាមួយគ្នារគេធ្លាប់និយាយអីអញ្ចឹង អើយកគ្នារទៅអីអញ្ចឹងទៅណា។

កះ ចាស។

ខះ អាណិតគ្នារអីអញ្ចឹងទៅ គេឃើញខ្ញុំស្លូតអីអញ្ចឹងហ្អា។

កះ ចាស។

ខះ ហើយដំពេលអញ្ចឹងអើ ក៏ប្ដីខ្ញុំគាត់ឮស្ងមិត្តភក្រ័គាត់ចេះតែថា ថាចោះហើយក៏គាត់តាមមករកខ្ញុំ ហើយចុះខ្ញុំសំឈប់ធ្វើការពីកន្លែងហ្នឹងអីអញ្ចឹងទៅ។

កះ ហ្អឺចាស។

ខះ ឃើញមានប្រុសៗច្រើនអញ្ចឹងខ្ញុំឈប់។

កះ ចាស។

ខះ ហើយគាត់តាមរកខ្ញុំ តាមអីដល់ផ្ទះអញ្ចឹង ទៅជួបម៉ែខ្ញុំទៅជួបខ្ញុំអីហ្នឹង សំខ្ញុំរៀបចំអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ព្រោះគាត់ គាត់ថាគាត់អត់មានលុយដែរ។

កៈ ចាស។

ខៈ ហើយម៉ែគាត់នៅឆ្ងាយ។

កៈ ចាស។

ខៈ ម៉ែគាត់នៅខេត្តក្រចេះហ្អរ។

កៈ ចាស។

ខៈ ហើយគាត់ធ្វើអី គាត់បង្ខំៗខ្លួនគាត់អញ្ចឹងទៅណា។

កៈ ចាស។

ខៈ គាត់យកលុយយកកាក់អោយម៉ែខ្ញុំមួយចំនួនអញ្ចឹងទៅ ដើម្បីរៀបចំអោយគាត់អញ្ចឹងទៅណា។

កៈ ចាស។

ខៈ ទៅបានបងប្អូន ខាងម៉ែខ្ញុំខាងអីគេចាប់ផ្ដើមរៀបចំរកអាចារកអីមើលពាលាមើលអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហើយគាត់ថា ព្រោះគាត់ប្រញាប់មកធ្វើការវិញអញ្ចឹងទៅ ព្រោះគាត់ត្រូវការអើអោយធ្វើអី។

កៈ លឿនលឿន។

ខៈ អោយធ្វើអោយលឿនៗអញ្ចឹងហ្អា គាត់ប្រញាប់ត្រលប់មកធ្វើការវិញអញ្ចឹងទៅណា។

កៈ ចាស។

ខ៖ ហ្នឹងហើយ ដល់ពេលហ្នឹងម៉ែខ្ញុំគាត់រៀបចំអោយបងប្អូនចាស់ទុំនៅស្រុកកំណើតហ្នឹង រៀបចំអោយទៅ។

ក៖ ចាស។ ចុះអើនាក់មីងចេះអាន នឹងសរសេរ នឹងនិយាយភាសារខ្មែរបានល្អប៉ុនណាដែរ?

ខ៖ ខ្ញុំអត់ចេះផង។

ក៖ អត់ចេះទាំងអស់ម៉ងមីងណា?

ខ៖ ចាស។

ក៖ ចាស ហើយចុះនាក់មីងចេះភាសារណាផ្សេងក្រៅពីភាសារខ្មែរហ្អេស?

ខ៖ អត់ទាំងអស់។

ក៖ អត់ទាំងអស់?

ខ៖ ហិហិហិហិ។

ក៖ អត់សោះម៉ង??

ខ៖ អត់សោះម៉ងហិហិ។

ក៖ ចាសចាស ចុះនាក់មីងរៀនបានត្រឹមថ្នាក់ ទីមាណដែរ?

ខ៖
ខ្ញុំរៀនត្រឹមថ្នាក់ទី ពី ប៉ុន្តែថ្នាក់ទីពីខ្ញុំរៀនអត់ អត់ចេះម៉ងហ្អា។ ព្រោះយើងវាអត់មាន ដូចថាយើងរៀននេះវាអត់ទៀងពេលអត់ទៅអត់ទាន់ម៉ោងអីហ្នឹងគេអីអញ្ជឹងទៅណា។

ក៖ ចាស។

ខ៖ ហ្នឹងហើយ ពេលអញ្ជឹងគ្រូអោយនៅក្រៅសាលារហូត។

ក៖ ហ្អរ ហើយចុះអើ នាក់មីងរៀននៅសាលាណាដែរ?

ខ៖ សាលាភុមិជង្រុក។

កៈ ភូមិជង្រុក? ចុះឈ្មោះសាលាឈ្មោះអី?

ខៈ ដឹងសាលាឈ្មោះអីទេកាលហ្នឹងរៀនរវល់តែឈឺ។

កៈ អត់ចាំ?

ខៈ អត់ចាំ។

កៈ ចាស ហើយចុះអើ តើនាក់មីងមានមិត្តភក្រ័ណាដែរស្និតស្នាល ហើយធំធាត់ឡើងមកជាមួយគ្នារហ្អេស?

ខៈ អត់មានទេ។

កៈ អត់មានសោះ?

ខៈ ហ្នឹងហើយ ហិហិហិហិ។

កៈ ហិហិហិហិ។

ខៈ អត់មានមិត្តភក្រ័ណាមួយ។

កៈ ចាស ហើយចុះអើ កាល? នាក់មីងធ្លាប់ធ្វើស្រែ ធ្វើចំការហ្អេស?

ខៈ ធ្លាប់តើ។ ខ្ញុំធ្វើស្រែឡើងរហូតដល់តែខ្ញុំមានប្ដីបានខ្ញុំលេងធ្វើ។

កៈ អញ្ចឹង?

ខៈ ធ្វើស្រែស៊ីឈ្នួលគេ។

កៈ ហ្អឺ។

ខៈ ព្រោះអើ អត់មានស្រែខ្លួនឯងធ្វើស៊ីតែឈ្នួលគេរហូតហ្នឹង ដឹងក្ដីពេលណាធ្វើតែខ្ញុំគេរហូត។

កៈ អញ្ចឹង?

ខៈ ហ្នឹងហើយ ម៉ែខ្ញុំគាត់ចេះតែដើរយកស្រែគេធ្វើ យកស្រែគេធ្វើអញ្ចឹងទៅ ចេះតែធ្វើហើយធ្វើមួយឆ្នាំមួយឆ្នាំទល់មួយឆ្នាំ។

ក៖ ហ្អឺ។

ខ៖ ធ្វើតែរបស់គេហ្នឹង។

ក៖ ចាស។

ខ៖ បើម៉ែខ្ញុំគាត់ដើរយករបស់គេចាយមុនអស់អញ្ចឹងទៅណា។

ក៖ ចាសចាស ហើយចុះអ៊ើ តើនាក់មីងធ្លាប់មានអាជីវកម្មជាលក្ខណៈគ្រួសារហ្អេស?

ខ៖ អាជីវកម្មរាល់តែថ្ងៃហ្អេស?

ក៖ ដូចជាធ្លាប់មាន ឬក៏រាល់ថ្ងៃមានហ្អេស? ដូចជាលក់ដូរជាលក្ខណៈគ្រួសារហ្អា?

ខ៖ អត់ អត់មានផង មានតែធ្វើការ។

ក៖ ធ្វើការ។

ខ៖ ចាស។

ក៖ ចាសចាស ហើយចុះអ៊ើ នាក់មីងតាំងពីក្មេងរហូតមកដល់ឥឡូវហ្អា? តើនាក់មីងឃើញថាជីវិតរបស់នាក់មីងមានការផ្លាស់ប្តូរអីខ្លះហ្អេស?

ខ៖ អ៊ើ ខ្ញុំផ្លាស់ប្តូរច្រើន ដោយសារ ផ្លាស់ប្តូរហ្នឹងដោយសារដំណឹងល្អរបស់ព្រះអីអញ្ចឹងហ្អា។

ក៖ ចាស។

ខ៖ បើអត់មានដំណឹងល្អនៃព្រះហ្អា ខ្ញុំក៏អត់មានការផ្លាស់ប្តូហើយខ្ញុំក៏អត់មានថ្ងៃនេះដែរ។

ក៖ ចាស។

ខ៖ ដោយសារអី? ដោយសារកាលខ្ញុំមិនទាន់អើជឿព្រះប្តីខ្ញុំគាត់ ចេះតែដើរមានស្រីមានញីអត់គិតប្រពន្ធកូនអីអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ គាត់ដូចថាដើររកស៊ី ដូចថារត់ម៉ូតូឌុប រត់អីអញ្ចឹងទៅណា ឌុបតែស្រីដើរអញ្ចឹងទៅ អត់ខ្វល់ថាខ្លាចប្រពន្ធអត់ស៊ីមានស៊ីអញ្ចឹងហ្អា ហើយខ្ញុំនៅផ្ទះខ្ញុំចេះតែខ្វាយខ្វល់ណាវាលុយចាយអត់គ្រប់ ហើយណាមួយវាអត់ទាន់មានដីមានផ្ទះអី និយាយរួបអត់មានទាន់មានជំហរអីរឹងមាំហ្អា។

ក៖ ចាសចាស។

ខ៖ ចាស ហ្នឹងហើយ ដើរសុំដីគេនៅអីអញ្ចឹងហ្អា។

ក៖ ចាស។

ខ៖ ហើយកូននៅតូចៗ ចេះតែគិតច្រើនខ្វាយខ្វល់ ហើយចេះតែដើរបេះត្រកួនបេះអីលក់ដើម្បីទិញម្ហូបអោយកូនហូបអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ ជួនកាលខ្ញុំដើរអើដក់ប្រលិត ដើរអើដក់ក្រអាវឈូក ដូចថាកូនខ្ញុំនៅតូចៗអញ្ចឹងទុកចងអង្រឹងទុកចោលនឹងរោងហ្នឹងទៅ។

ក៖ ចាស។

ខ៖ ទុកកូនអញ្ចឹងខ្ញុំដើរចោលបាត់ហើយ ខ្ញុំដើរដូចជាដើរបកចង់អីអញ្ចឹង ហ្អរគេហៅធ្វើអីធ្វើហ្នឹង។

ក៖ ចាសចាស។

ខ៖ ការងារអីក៏ដោយអោយតែគេហៅធ្វើអីធ្វើហ្នឹង អោយតែបានលុយកាលហ្នឹងហ្អា។

ក៖ ចាស បង ចាស។

ខ៖ ដល់ពេលខ្ញុំស្គាល់ដំណឹងល្អ ដូចថាខ្ញុំថាមានការផ្លាស់ប្តូរច្រើន ដូចថាខ្ញុំមានលត្តភាពជួលផ្ទះគេនៅ ខ្ញុំមានកាងាល្អធ្វើ រួចហើយខ្ញុំជួបគ្រួសារល្អដែរគាត់ចេះកែប្រែអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ គាត់កែពី កែប្រែពីទម្លាប់អាក្រក់មកល្អច្រើនអញ្ចឹងទៅណា។

កៈ ចាស អញ្ចឹង?

ខៈ គាត់ចេះស្រឡាញ់ប្រពន្ធកូន គាត់ចេះស្រឡាញ់ក្រុមគ្រួសារ។

កៈ ចាស។

ខៈ ហ្នឹងហើយ ដល់ពេលអញ្ចឹងគាត់មានស្រីមានញី គាត់ឈប់ធ្វើអោយយើងពិបាកចិត្តអីអញ្ចឹងទៅណា។

កៈ ចាស អញ្ចឹងមានន័យថាឥឡូវនោក់មីងសប្បាយចិត្តជាងមុន?

ខៈ ចាស សប្បាយជាងមុន ដូចថាដំណឹងល្អរបស់ព្រះ ស្គាល់ដំណឹងល្អរបស់ព្រះអញ្ចឹងទៅណា។

កៈ ហើយក៏ធូធាជាងមុនដែរណា?

ខៈ ចាស ហើយក៏លែងពិបាក ដូចមុនដែរ។

កៈ ចាស ហើយចុះអើ តើនាក់មីងចូលចិត្តញាំម្ហូបអីគេ?

ខៈ និយាយរួមរឿងម្ហូបអីក៏ចូលចិត្តដែរ ហិហិហិហិ។

កៈ ហិហិហិ ចូលចិត្តញាំសម្លរអី?

ខៈ ចាស។

កៈ ត្រីចៀន ឬក៏អីអញ្ចឹងហ្អា?

ខៈ ចូលចិត្តញាំស្លរត្រពាំង រួចចូលចិត្តស្លរគគូ ឬស្លរប្រហើអីអញ្ចឹងទៅណា។

កៈ ម្ហូបខ្មែរ?

ខៈ ចូលចិត្តម្ហូបខ្មែរ ហិហិហិហិ។

កៈ ចាស ចុះសំរាប់ល្បែងប្រជាប្រិយ៍វិញ តើនាក់មីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរតាំងពីក្មេង?

ខ៖ តាំងពីក្មេងខ្ញុំចូលចិត្តរាំ។

ក៖ ហ្អេរ ចូលចិត្តរាំហ្អេរ?

ខ៖ ហ្នឹងហើយ ស្រឡាញ់ណាស់។

ក៖ ហ្អឺ។

ខ៖ ចូលចិត្ត ហិហិហិ ចូលចិត្តថាមាន តាំងពីក្មេងមានកម្មវិធីបុណ្យអីណា ក៏អត់ដៃរចោលដៃរ រាំទាល់តែបាស់ចប់។

ក៖ ហ្អេរ ហិហិហិហិហិហិ។

ខ៖ មែនតើ រាំទាល់តែបាស់សុំចាញ់ តែពីនៅពីនាក់ក៏រាំដៃរ ។

ក៖ ចាសចាស។

ខ៖ ទាល់តែគេបិទម៉ង។

ក៖ ចាស។

ខ៖ ចូលចិត្តណាស់។

ក៖ ចាស។ ហើយចុះចម្រៀងវិញ តើនាក់មីងចូលចិត្តអើ ចម្រៀងណាដៃរដូចជា តើអើនាក់ណាតារាចម្រៀងណាដៃរនាក់មីងចូលចិត្ត? ហើយឬក៏មានចម្រៀងណាដៃរនាក់មីងបានរៀនពីក្មេងហើយនៅតែចងចាំហ្អេស?

ខ៖ ខ្ញុំចូលចិត្តតែបទ សុន ស៊ីសាមុត នឹង រស់ សេរីសុទ្ធា។

ក៖ អញ្ចឹងចូលចិត្តសុន ស៊ីសាមុត នឹង រស់ សេរីសុទ្ធា?

ខ៖ ហ្នឹងហើយ ស្រឡាញ់បទ គាត់ច្រៀង។

ក៖ ពិរោះ?

ខ៖ ពិរោះ។

កៈ ហ្អរ។

ខៈ ហិហិហិ។

កៈ ចាស ចូលចិត្តបទពីដើម ពីដើម?

ខៈ ចាស បើថាបទឥឡូវស្តាប់មិនសូវចូលទេ ហិហិហិហិ។

កៈ ហិហិហិហិហិ។

ខៈ ហ្នឹងបានតែក្មេងៗហ្អេស។

កៈ ចុះអើ តើនៅក្នុងក្រុមគ្រួសារននាក់មីងមាននណាគេចេះលេងឧករណ៍ភ្លេងហ្អេស?

ខៈ អត់មានផង។

កៈ អត់សោះម៉ង?

ខៈ ចាស។

កៈ ចាស ចុះអើផ្ទះរបស់នាក់មីងតាំងពីមីងនៅក្មេងហ្អា? នៅតាំងពីក្មេងហ្អាមានលក្ខណៈមេចដែរ? ដូចជាផ្ទះថ្ម ឬក៏ផ្ទះឈើ?

ខៈ អើ ផ្ទះខ្ទម។

កៈ ផ្ទះខ្ទម?

ខៈ ផ្ទះខ្ទមម៉ង។

កៈ ហើយផ្ទះហ្នឹងជា?នាក់ណាជានាក់សាងសង់វាឡើងដែរមីង? ឬក៏មីងបានជួយសាងសង់វាអត់?

ខៈ អើ កាលហ្នឹងដូចការពីដំបូងហ្នឹង ខ្មោចយាយខ្ញុំគាត់នាក់សាងសង់ ដូចជាមានគេធ្វើអោយគាត់អញ្ចឹងទៅណា ផ្ទះខ្ទមគាត់ ដ៏ពេលខ្ញុំបានការ ខ្ញុំការហើយ អើប្តីប្រពន្ធខ្ញុំដើរកាប់ស្លឹក ដើរសុំឫស្សីគេ សុំឈើគេនាក់ជិតខាងអីអញ្ចឹង ដើម្បីយកមកធ្វើខ្ទមនៅបែកពីម៉ែពីឪអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ដើរ និយាយរួបប្រវត្តិប្តីប្រពន្ធខ្ញុំតស៊ូណាស់។

កៈ ហ្អឺ។

ខៈ តស៊ូដើរកាត់ស្លឹក ដើរកាត់អាកូនស្លឹកតូចៗហ្អរ។

កៈ ចាស។

ខៈ ដើរកាត់យកមកហើយដេរ ដេរហើយយកត្រាំទឹកទៅ ប្រកដើម្បីធ្វើខ្ទមនៅបែកទៅ នឹកឃើញថានៅជុំយើងផ្ទះខ្ទមនៅជុំគ្នារវេចង្កៀតនៅអត់កើត។

កៈ ចាស។

ខៈ ដល់ពេលអញ្ចឹងដើរសុំឫស្សី សុំឈើគេអញ្ចឹងបានមួយដើមពីដើមមកដើម្បីយកមកធ្វើខ្ទម នៅអញ្ចឹងទៅណា។ ហើយដើរកាប់ស្លឹកត្នោត ដើរកាប់ស្លឹកត្នោតមានអីវែកតាំងពីណាពីនៃ មានអីជឹកដូចឥឡូវទេ មានតែវែក ។

កៈ ចាស។

ខៈ ចាស ប្រវត្តិប្តីប្រពន្ធខ្ញុំគិតទៅ គឺថាល្វីងជូជត់ថាតស៊ូជាមួយគ្នារមែនទែន បើថានាក់ នាក់អត់ចេះគិតហ្អា គេមិននៅតស៊ូជាមួយយើងហ្អេស។

កៈ ចាស។

ខៈ ខ្ញុំគិតអញ្ចឹង ខ្ញុំថាអញ្ចឹងបានខ្ញុំស្រឡាញ់គោរបប្តីខ្ញុំដោយសារអី គាត់តស៊ូជាមួយខ្ញុំហ្អាណា ។

កៈ ចាស។

ខៈ
រហូតដល់បាតដៃទទេសុទ្ធសាទ គាត់ទ្រាំ គាត់អើទ្រាំជាមួយយើងបានហ្អា បើប្រុសខ្លះហ្អា ខ្ញុំថារត់ចោលយើងបាត់ហើយ គេអត់មាននៅទ្រាំទ្រជាមួយយើងទេ។

កៈ ចាសចាស។

ខៈ ចាស ហើយរហូតដល់អើ
 គាត់មកនៅយកខ្ញុំមកនៅផ្ទះបងថ្លៃ បងថ្លៃនៅមិនបាន នៅផ្ទះជាមួយអី អ៊ីហ្នរ។

កៈ ចាស។

ខៈ ហ្នឹងនៅទៅមិនបានមិនអីអញ្ចឹងចេះតែដៃរសុំដីគេអីទៅ ដើម្បីស្នាក់អាស្រ័យអញ្ចឹងទៅណា ។

កៈ ចាសចាស។

ខៈ ហ្នឹងហើយ។

កៈ ហើយចុះអើ ផ្ទះហ្នឹងបងគិតថាត្រូវការសំភារះអីខ្លះដើម្បីសង់ដែរ?

ខៈ អើសំភារះមានដែកគោល មានអីអញ្ចឹងចេះតែដើរ។

កៈ មានឈើ។

ខៈ មានឈើ មានឬស្សី មានខ្សែរមានអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហើយមាន និយាយរួបខ្វះខាតច្រើនមែនទែនទៅណា ដោយសារអានេះបានយើងអើជួយ នាក់ជិតខាងជួយផងអីផងអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហើយលុយយើងរកអានេះមកបានតិចតួចមកទិញដែកគោលទិញអីដើម្បីធ្វើជួសជុល ធ្វើមិចទំរាំតែបាននៅយូណាស់ណា។

កៈ ចាសចាស។

ខៈ ធ្វើជំនាន់កាលហ្នឹងយើងអត់ទាន់មានលុយមានកាក់អីទេ។

កៈ ចាស។

ខៈ ក្រមែនទែន គេហៅក្រ គេហៅមិនមែនត្រឹមក្រទាល់មង។

កៈ ចាសចាស។

ខៈ ហើយកាលហ្នឹងមិនទាន់មានការងារអីធំដុំធ្វើទេ។

កៈ ចាស ហើយចុះអើ នាក់មីងមានជំនាញណាដែរនាក់មីងចេះតមកពីគ្រួសារមីងហ្អេស?

ខៈ ខ្ញុំដូចអត់មានជំនាញអីផង។

កៈ អត់មានទេណា?

ខៈ ចាស។

កៈ ចាស ចុះអើ តើនាក់មីងអាចប្រាប់ខ្ញុំបានហ្អេស ថាពេលណាដែរនាក់មីងលំបាកបំផុតក្នុងជីវិតរបស់នាក់មីងហ្អា?

ខៈ លំបាកបំផុតក្នុងជីវិតខ្ញុំហ្អា?

កៈ ចាស។

ខៈ លំបាកបំផុតអើ ម៉ែខ្ញុំធ្វើបាបអីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហើយដល់ពេលម៉ែខ្ញុំធ្វើបាបពេក ម៉ែខ្ញុំគាត់ចេះតែផឹកស្រវឹង ផឹកស្រវឹងរាល់តែថ្ងៃអញ្ចឹងធ្វើអោយកូនគ្មានការកក់ក្ដៅធ្វើអោយលែងចង់រស់នៅក្នុងផ្ទះអញ្ចឹងទៅណា។ ដល់ពេលអញ្ចឹងខ្ញុំចេះតែចេញដើរទៅនៅជាមួយគេនោះបន្តិច ទៅនៅជាមួយគេណោះមួយឆ្នាំពីឆ្នាំ ទៅនៅជាមួយគេនេសមួយឆ្នាំពីឆ្នាំ ចេះតែដើរនៅរហូតទៅណា។

កៈ ចាស។

ខៈ ដើរ ដល់ដើរនៅទៅបានរហូតបានជួបប្ដីខ្ញុំហ្នឹងណា។

កៈ ហ្អរ។

ខៈ ខ្ញុំអត់ដែរនៅផ្ទះទេ ព្រោះខ្ញុំអត់ចេះនៅផ្ទះជាមួយម៉ែខ្ញុំអញ្ចឹងទេ។

កៈ ចាស។

ខៈ ព្រោះម៉ែខ្ញុំគាត់ផឹកស្រាស្រវឹងអី ជេប្រទីក ជេប្រទីកអញ្ចឹងខ្ញុំអត់ចេះនៅ។

កៈ

ចាស។ ហើយចុះ ទោះបីជាជីវិតរបស់នាក់មីងបានមានការលំបាក តើមីងបានឆ្លងកាត់វាមកបានយ៉ាងដូចម្ដេចដែរ?

ខៈ ខ្ញុំឆ្លងកាត់ ដោយសារខ្ញុំបានប្ដីខ្ញុំលំបាកមួយជាន់ទៀត។

កៈ ហ្អរ។

ខៈ ប្ដីខ្ញុំធ្វើបាបមួយជាន់ទៀត។

កៈ ចាស។

ខៈ ប្ដីខ្ញុំធ្វើបាបមួយជាន់ទៀត ដូចគាត់វៃគាត់អីអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ហើយដូចថាគាត់មានអើ ស្រីមានអីអញ្ចឹងគាត់ចេះតែមោម៉ៅ រករឿងយើងអីអញ្ចឹង ដូចថាមើលមកយើងក្នុងផ្ទះអាក្រក់រហូតហ្នា ដូចថាមើលមកយើងដូចថាអត់មានអីល្អ ដូចថាល្អកន្លែងណាម៉ងហ្អាណា។

កៈ ចាស។

ខៈ ហ្នឹងហើយ ដ៏ពេលអញ្ចឹងគាត់ចេះតែមោម៉ៅរករឿងជេបញ្ចោរវៃអីអញ្ចឹងទៅ ខ្ញុំទៅក៏ចាប់ផ្ដើមដើរទៀតហើយ បានកូនមួយហ្នឹងអាបងគេហ្នឹង ចាប់ផ្ដើមដើរទៀតហើយ រហូតដល់មកនៅផ្ទះបងឈ្មោះគ្នាវខ្ញុំអីអញ្ចឹងហ្អា ដ៏អញ្ចឹងខ្ញុំធ្វើការនៅរោងចក្រកៅស៊ូនៅច្បារអំពៅហ្នឹង។

កៈ ចាស។

ខ៖ ធ្វើការបង់ អើបង់លុយខ្ចី លុយអើលុយទិញម៉ូតូទិញអីគាត់រត់ឌុបហ្អារ។

ក៖ ចាស។

ខ៖ ធ្វើការបង់លុយគេ បង់អីហើយគាត់អត់រត់ទេ គាត់ទៅឌុបស្រីដើរទៅអីអញ្ចឹងហ្អា។

ក៖ ចាស អញ្ចឹងបងខំប្រឹង?

ខ៖ ចាស។

ក៖ បងបានខំប្រឹងប្រែមករហូតដល់សព្វថ្ងៃណា?

ខ៖ ចាស។ដល់ពេលអញ្ចឹង គាត់ចេះតែ ដូចថាអត់ទាន់មានចេះគិតអីម៉ង គាត់គិតតែពីសប្បាយតែខ្លួនគាត់ម៉ងអញ្ចឹងហ្អាណា។

ក៖ ចាស។

ខ៖ ដល់ពេលអញ្ចឹងទៅខ្ញុំលំបាកមួយជាន់ហ្នឹង ខ្ញុំលំបាកដល់រហូតដល់ខ្ញុំឡើងស្គមខ្លួនហ្អា។

ក៖ ចាស។

ខ៖ ថាឡើងស្គម ថាថានៅតែ៤០គីឡូហ្អេ។

ក៖ ចាស។

ខ៖
ខ្ញុំដូចថាខ្ញុំគិតច្រើន ហើយពិបាកចិត្តប្តីមានស្រីផង ហើយមនុស្សស្រីយើងជាធម្មតាទេតែប្តីមានស្រីវាគិតច្រើនហើយណា ធ្វើការផងហើយរកលុយដោះគេផង ហើយដល់ពេលអញ្ចឹងគិតច្រើនគិតច្រើនរហូតដល់ខ្ញុំចង់អើខូចខួរក្បាលកាលហ្នឹង ហើយដល់ពេលចុងក្រោយឡើងប្តីខ្ញុំគ្រាន់តែនិយាយជាមួយប្តីមួយម៉ាត់ទេ ថាអើបានស្វាយអីអញ្ចឹង កាលហ្នឹងជំនាន់ហ្នឹងវាដូចថាក្រពិបាកអញ្ចឹង ដូចថាបានអីតិចតួចមកសុកចិត្តអោយស្រីហ្អា ប្រពន្ធអត់អោយស៊ីអញ្ចឹងលាក់លៀបអោយស្រីគេអញ្ចឹង ពេលខ្ញុំថាទៅមកដល់វៃយើងអីយើងអញ្ចឹងទៅណា ដល់ពេលអញ្ចឹងហើយវៃអញ្ចឹងខ្ញុំរត់ទៅស្រុក តិចទៅស្រុក តិចទៅស្រុកនៅអត់កើតអញ្ចឹង មកផ្ទះបងថ្លៃអីអញ្ចឹងវិញទៅណា។

កៈ ចាស។

ខៈ មកកន្លែងធ្វើការ កន្លែងអីវិញអញ្ចឹងទៅ ដល់ពេលអញ្ចឹងប្តីខ្ញុំគាត់ចេះតែអើ ដូចថានឹកកូននឹកអីអញ្ចឹង គាត់ចេះតែតាមទៅយកមកវិញមក កុំអោយតាមប្តីអញ្ចឹងទៅ។

កៈ ហ្អរចាស។

ខៈ ហ្នឹងហើយ ដូចថាគាត់នឹកកូនអញ្ចឹងហ្អា តាមមកវិញមកតាមប្តី អញ្ចឹងចុះបើនៅស្រុកអត់កើតហ្អរ ដ៏ពេលអញ្ចឹងខ្ញុំចេះតែតាមប្តីអើយ ដល់ពេលអញ្ចឹងចូលទៅដល់រៀនអង្គការរហូតដល់តែខ្ញុំទៅប្តឹងអង្គការគេ អង្គការសិទ្ធមនុស្សហ្អរ។

កៈ ចាស។

ខៈ ប្តឹងអង្គការទៅ គេហៅប្តីទៅប្រជុំ ទៅអប់រំ ទៅនៃនាំអញ្ចឹងទៅគាត់ចាប់ផ្តើមកែបន្តិចម្តងបន្តិចម្តងអញ្ចឹងទៅណា។

កៈ ចាស។

ខៈ ចុងក្រោយឡើងគាត់វៃខ្ញុំទៀត វៃខ្ញុំដេញខ្ញុំចេញពីផ្ទះទៀត។

កៈ ចាស។

ខៈ ដេញខ្ញុំចេញពីផ្ទះ ខ្ញុំទៅកន្លែងការងារម៉ែខ្ញុំគាត់នៅជាមួយគេ នៅប្រែកប្រាហ្អា។

កៈ ចាស។

ខៈ ខ្ញុំទៅហ្នឹង ខ្ញុំបបួលម៉ែខ្ញុំ ទៅស្រុក កូនខ្ញុំ ខ្ញុំមានកូនទីពីហើយ។

កៈ ចាស។

ខៈ កូនទីពីនៅតូច។

កៈ ចាស។

ខៈ ទើបតែចេះវា ដល់ពេលអញ្ចឹងជួបទៀតហើយ។

កៈ ហ្អឺ។

ខៈ
 ជួបទៀតហើយ ទៅទៅចោលនេះទៀតហើយ ទៅចោលហើយដល់ពេលមកដល់ គាត់ថាមកដល់អត់ឃើញប្រពន្ធកូននៅផ្ទះដូចថាគាត់អត់ចេះនៅ គាត់មកតាមរកទៀតហើយ តាមរករករកដល់ពេលទៅរងចាំអាផ្ទះខ្ញុំអើស្នាក់ហ្នឹង ក៏ម្ចាស់ផ្ទះហ្នឹងគាត់ចិត្តធម៌ទៀត គាត់ថាអោយមុនហ្នឹងអោយខ្ញុំចេញមកគាត់នៃនាំប្ដីខ្ញុំគាត់អោយប្ដីខ្ញុំដាក់ល័កខណ្ឌ័ជាមួយគាត់ហ្អា។

កៈ ចាស។

ខៈ ហ្នឹងហើយ គាត់អោយដាក់ល័កខណ្ឌ័ថាឈប់ធ្វើបាបគ្នារឈប់ដេញគ្នារ ធម្មតាមនុស្សស្រីតែធ្វើបាបគេពេកមាននណានៅជាមួយកើតទេ គេជេណា គេជេ។

កៈ ចាស។

ខៈ ដល់អញ្ចឹងហើយ ក៏ក៏គាត់យល់ព្រម ដល់ពេលចាប់ពីចុងក្រោយហ្នឹងមក គាត់ថាមកដល់ផ្ទះគាត់និយាយជាមួយខ្ញុំហ្អា គាត់ថា គាត់ថាមានតែខាងសាសនាយ៉េស៊ូទេដែរអាចកែវិញ្ញាណគាត់បានហ្អា។

កៈ ចាស។

ខៈ គាត់និយាយពាក្យហ្នឹងជាមួយខ្ញុំបានខ្ញុំជឿជាក់ ដល់ពេលស្អែកឡើងគាត់ដើរសួររកព្រះវិហារអញ្ចឹងទៅណា។

កៈ ចាស។

ខៈ
 សួររកព្រះវិហារមិនមែនចូលខាងយើងមុនទេ ចូលខាងអើបាទីស្ទឯករាជ នៅអើខាងជើងវិមានឯករាជហ្អរ។

កៈ ចាស។

ខៈ ហើយទៅថ្វាយបង្គំយប់ទៀតថ្ងៃហ្នឹង។

កៈ ចាស។

ខៈ ទៅថ្វាយបង្គំម៉ោងប្រាំដល់ម៉ោងប្រាំបួនយប់។

កៈ ចាសចាស។ ឃើញថាអើជីវិតរបស់នាក់មីងមានការលំបាកច្រើន។

ខៈ ហ្នឹងហើយ។

កៈ ឆ្លងកាត់មកច្រើន។

ខៈ ច្រើនណាស់និយាយរួប។

កៈ តែតស៊ូមកក៏ឥឡូវក៏ល្អប្រសើរជាងមុន។

ខៈ ចាស អានេះល្អដោយសារដំណឹងល្អទេ។

កៈ ចាស ហិហិហិហិហិ។

ខៈ ហិហិហិហិហិ។

កៈ ចាស អញ្ចឹងអើ តើជីវិតរបស់នាក់មីងមានបទពិសោធន៍ណាដែរសប្បាយខ្លះហ្អែស? នៅក្នុងជីវិតហ្អា?

ខៈ ដូចអត់មានផង។

កៈ អត់មានសោះម៉ង?

ខៈ ហ្នឹងហើយ។

កៈ ហ្អរចាស ហើយចុះអើ នាក់មីងតាំងពីក្មេងរហូតមកដល់ឥឡូវ តើនាក់មីងធ្លាប់មានបំណងប្រាថ្នាឬក្តីស្រមៃអី ដែរនាក់មីងចង់បានទៅថ្ងៃអនាគត់ហ្អែស?

ខៈ អើ ខ្ញុំមានបំណង ខ្ញុំបំណងខ្ញុំតាំងពីខ្ញុំនៅក្មេង ព្រោះខ្ញុំឃើញទង្វើម្តាយរបស់ខ្ញុំ ខ្ញុំអើ បំណងរបស់ខ្ញុំ ខ្ញុំសុំតែអោយមានគ្រួសារអត់ចេះជក់បារី អត់ចេះផឹកស្រាអីអញ្ចឹង ខ្ញុំចង់បានតែមួយហ្នឹងហ្អែស។

ក៖ ចាស។

ខ៖ ហើយខ្ញុំជួបមែន ជួបដោយពិនប្រាកដមែន។

ក៖ អត់ចេះ?

ខ៖ អត់ចេះអីទាំងអស់ ចេះតែស្រី។

ក៖ ហិហិហិហិហិហិហិ ប៉ុន្តែឥឡូវគាត់បានផ្លាស់ប្តូរហើយ?

ខ៖ ហ្នឹងហើយ ផ្លាស់ប្តូរអស់ហើយ។

ក៖ ចាស
ចាស អញ្ចឹងអើ បើសិនជានាក់មីងអាចមានឧកាសផ្តាំផ្ញើរដល់កូនចៅជំនាន់ក្រោយរបស់នាក់មីង តើនាក់មីងចង់និយាយអីខ្លះទៅកាន់ពួកគាត់ហ្មែស? ថាដូចជាតើនាក់មីងចង់អោយកូនចៅជំនាន់ក្រោយមីងហ្នឹង ក្លាយជាមនុស្សបែបណា? អោយអោយពួកគាត់មានភាពជោកជ័យអីខ្លះក្នុងជីវិតហ្អា?

ខ៖ ខ្ញុំចង់អោយអើ ពួកគាត់អើកុំមើលតាមគំរូ ដែរមិនមនុស្សមិនល្អអីអញ្ចឹងហ្អា។

ក៖ ចាស។

ខ៖ អោយមើលតែកំរូដែរអើ ព្យាការីបាននែនាំដូចព្យាការីបានបង្រៀនអីអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ ខ្ញុំអោយមើលឃើញគំរូតាមអើយ សាសនាចក្ររបស់យើងអញ្ចឹងហ្អា។

ក៖ ចាស។

ខ៖ ហ្នឹងហើយ ហើយអោយធ្វើអ្វីដែរត្រឹមត្រូវ ធ្វើអ្វីដែរសុទ្ធរិត កុំអោយធ្វើអ្វីដែរផ្តេសផ្តាសអីអញ្ចឹងហ្អា ហើយសូមអោយដឹងគុណឪពុកម្តាយ កុំអោយអើយ ធ្វើអោយឪពុកម្តាយពិបាកចិត្ត កុំអោយឪពុកម្តាយទឹកភ្នែកដោយសារកូនអីអញ្ចឹងហ្អាកុំ ធ្វើអោយឪពុកម្តាយពិបាក ធ្វើអោយរីករាយឡើងអីអញ្ចឹងហ្អា។

ក៖ ចាស។

ខ៖
 អញ្ចឹងបានថា គ្រួសារមានសុភមង្គល ហើយសូមអោយជួយឪពុកម្ដាយអោយបានច្រើន ហើយចេះគិតគូពីពួកគាត់អីអញ្ចឹងហ្មាណា។

ក៖ ចាស។

ខ៖
 ព្រោះពួកគាត់ប្រឹងប្រែងរក រកស៊ីអោយកូនរាល់ថ្ងៃដើម្បីចង់អោយកូនចេះដឹង ចង់អោយកូនមានបាន អត់មានឪពុកម្ដាយណាចង់អោយកូនក្រទេ។

ក៖ ចាស។

ខ៖ ឪពុកម្ដាយអត់មានចំណេះ។

ក៖ ចាស។

ខ៖ អត់មានចំណេះ ដល់ពេលកូនខំប្រឹងប្រែងដើម្បីអោយកូនមានចំណេះដឹង។

ក៖ ចាស។

ខ៖ ដើម្បីកុំអោយពិបាក
ដូចពួកឪពុកម្ដាយអញ្ចឹងទៅណា ឪពុកម្ដាយតែអត់ចំណេះពិបាក ពិបាកតកូនហ្មា។

ក៖ ចាសបងចាស។

ខ៖ ហើយនឹងបើឪពុកម្ដាយចេះគិត បើឪពុកម្ដាយអត់ចេះគិតទៀតហ្មា កូនកាត់តែទៅហើយ។

ក៖ ចាស។

ខ៖ ហ្នឹងហើយ នេះខ្ញុំជឿ ខ្ញុំចូលសាសនាចក្រមួយនេះ ដោយសារខ្ញុំគិតកូនហ្មេស។

ក៖ ចាស។

ខ៖ ខ្ញុំចង់អោយកូនល្អ ខ្លាចតែកូនធ្លាក់ក្នុងអើ អំពើអាក្រក់មួយណាអញ្ចឹងហ្មា។

ក៖ ចាស។

ខ៖
 អញ្ចឹងបានខ្ញុំចូលមកហ្នឹង ចូលសាសនាយើងនេះដើម្បីអោយកូនមានជួបមនុស្សល្អទៅ ពួកគាត់ចេះកែប្រែគាត់មានដំណើងល្អក្នុងខ្លួន គាត់ចេះគិត គាត់មានបញ្ញាតិព្រះអញ្ចឹងហ្អា។

ក៖ ចាសចាស។

ខ៖ ហ្នឹងហើយ។

ក៖ អញ្ចឹងអើ បងមានអីទៀតហ្អេស?

ខ៖ ដូចថាកូនកូនខ្ញុំ កូនកូនខ្ញុំសុទ្ធតែប្រុស។

ក៖ ចាស។

ខ៖ ដល់ពេលអញ្ចឹងទៅ អនាគត់ទៅមុខទៅ អត់មានសង្ឃឹមអីបានទេ ព្រោះគេធំៗឡើងគេរកស៊ីចញ្ចឹមប្រពន្ធកូនគេអស់ហើយ។

ក៖ ចាស។

ខ៖ ដល់តែពេលអញ្ចឹង យាយតាខ្ញុំហ្នឹងពិបាកហើយដោយសារអត់មានកូនស្រី។

ក៖ ហាហាហាហាហា។

ខ៖ ហ្នឹងហើយ សុទ្ធតែកូនប្រុសអញ្ចឹង ដូចអត់មានសង្ឃឹមទេ។

ក៖ ចាស។

ខ៖ ហ្នឹងហើយ ហើយខ្ញុំប្រឹងប្រែងដើម្បីអី ដើម្បីអោយគាត់រៀនយកចំណេះចេះដឹងទៅគាត់ មានចញ្ចឹមពួកខ្ញុំណាចញ្ចឹមប្រពន្ធកូនគេដដែរហ្នឹង។

ក៖ ហ្នឹងហើយ ហាហាហាហា។

ខ៖ ហ្អឺ ដោយសារយើងអត់មានអីចែកពួកគាត់។

ក៖ ចាស។

ខ៖ ដំអញ្ចឹងមានតែចំណោះហ្នឹងហើយចែកពួកគាត់ហ្អរ។

ក៖ ចាស។

ខ៖
 យើងអត់មានទ្រព្យសម្បត្តិអីចែកពួកគាត់ហ្អេស គាត់បានចំណោះរបស់គាត់ បានអើមុខជំនាញរបស់គាត់ជាប់ខ្លួនពិតប្រាកដ។

ក៖ ចាស។

ខ៖ គាត់អាចទៅរកកូនគេនាក់គួសន្យហ្អា។

ក៖ ចាស។

ខ៖ ហ្នឹងធូធាគាត់ស្រួលគាត់នោះហ្នឹង។

ក៖ ចាស។

ខ៖ មិនមែនស្រួលយើងណា។

ក៖ ហ្នឹងហើយ ហិហិហិហិហិ។

ខ៖ ហិហិហិហិ ពិបាកយើងដដេរហ្នឹង។

ក៖ ចាស។

ខ៖ ដំពេលអញ្ចឹងអោយគាត់មានបានធូធាទៅយើងក៏សប្បាយចិត្តដែរឪពុកម្តាយហ្អរ។

ក៖ ចាសចាស។

ខ៖ មាននណាចង់អោយកូនពិបាកដូចយើង មាននណាចង់អោយកូនក្រដូចយើងទេ។

ក៖ ចាសចាស។

ខ៖ ហ្នឹងហើយ។

កៈ ត្រូវហើយចាស។

ខៈ ចាស។

កៈ អញ្ចឹងអរគុណច្រើនបងណា។

ខៈ ចាស។

កៈ ហើយអញ្ចឹងឥឡូវខ្ញុំអស់សំនួរហើយ ហើយខ្ញុំអរគុណច្រើនអើដែរបានចំណាយពេលពិភាក្សានឹងប្រាប់ខ្ញុំអំពីប្រវត្តិរបស់នាក់មីងអញ្ចឹងទៅណា។។

ខៈ ហ្នឹងហើយ។

កៈ ហើយអើយ កាលសំភាសន៍នេះខ្ញុំហ្នឹងយកទៅដាក់ចូលទៅក្នុងវេបសាយ៍របស់សាលាbyu ហ្អា។

ខៈ ហ្អឺ។

កៈ ដែរមានឈ្មោះថា www.cambodaioralhitries.byu.edu អញ្ចឹងតើនាក់មីងអនុញ្ញាតិដើម្បីអោយខ្ញុំយកការសំភាសន៍របស់នាក់មីងដាក់ចូលទៅក្នុងវេបសាយ៍របស់សាលាbyuហ្អេស?

ខៈ អនុញ្ញាតិតើ។

កៈ ចាស អញ្ចឹងអរគុណច្រើន។

ខៈ ហ្នឹងហើយហិហិហិហិ។

កៈ ហើយខ្ញុំដឹងថាអ្វីដែរនាក់មីងបានចែកចាយហើយផ្តាំផ្ញើរវាហ្នឹងជួយដល់កូនចៅជំនាន់ក្រោយរបស់នាក់មីងពិតប្រាកដមែន។

ខៈ ចាស។

កៈ ហើយខ្ញុំដឹងថាមេរៀនទាំងអស់ គាត់នឹងរៀនច្រើនអំពីបទពិសោធន៍នៅក្នុងជីវិតរបស់នាក់មីងអញ្ចឹងទៅណា។

ខៈ ចាស។

កៈ ចាស អញ្ចឹងអរគុណច្រើនណាមីងណាដែរបានចំណាយពេល។

ខៈ ហិហិហិហិហិ។

(ការសង្ខេបពីខ្ញុំនិមល ខ្ញុំចូលចិត្តត្រង់ថាបទពិសោធន៍ប្ដីគាត់ គឺជាមនុស្សមិនល្អ តែសាសនាចក្រព្រះយេស៊ូគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ អាចជួយផ្លាស់ប្ដូរគាត់បាន។ ខ្ញុំក៏ជឿបែបនេះដែរ)